# ភ្នំពេញ – សៀមរាប (៣ថ្ងៃ២យប់)

## ថ្ងៃទី១ : ភ្នំពេញ_សៀមរាប_អង្គរវត្ត (អាហារ ២ពេល)



ធ្វើដំណើរពីភ្នំពេញឆ្ពោះទៅខេត្តសៀមរាបតាមផ្លូវជាតិលេខ៦។គយគន់ទេសភាពព្រៃព្រឹក្សាខៀវស្រងាត់និងទទួលទានអាហារថ្ងៃនៅទីរួមខេត្តរួចបន្តដំណើរទៅកំសាន្តនៅ ប្រាសាទអង្គរវត្ត ដែលជាប្រាសាទមួយកសាងឡើងនៅដើមសតវត្សទី១២ ក្នុងសម័យអង្គរដែលមានចំលាក់ក្បូរក្បាច់រចនារស់រវើកដ៏ល្អវិចិត្រ ល្បីល្បាញគ្មានគូរប្រៀបបានប្រកួតបាននូវស្នាដៃដ៏ប៉ិនប្រសព្វរបស់បុព្វបុរសខ្មែរកាលពីសម័យមហានគរដ៏រុងរឿងនៃអាណាចក្រខ្មែរបន្ទាប់មកបន្តដំណើរទៅទស្សនានៅប្រាសាទតាព្រហ្ម ប្រាសាទភ្នំបាក់ខែង និងគយគន់ទេសភាពនៃព្រះអាទិត្យលិចដ៏ស្រស់ត្រកាលនៅលើកំពូលភ្នំ។អាហារពេលល្ងាចយ៉ាងឆ្ងាញជាប់ចិត្តត្រលប់ទៅសណ្ឋាគារ។

## ថ្ងៃទី២ : សៀមរាប_ភូមិវប្បធម៌_អង្គរធំ (អាហារ ៣ពេល)



អាហារពេលព្រឹករួចជូនទៅទស្សនារមណីយដ្ឋានអង្គធំ ដែលសំបូរទៅដោយប្រាសាទល្បីៗជាច្រើនជាពិសេសប្រាសាទបាយ័ន ,ប្រាសាទបាពួនភិមានអាកាស ដែលជាប្រាសាទ ដ៏អស្ចារ្យ បន្ទាប់ពីប្រាសាទអង្គរវត្ត។ អាហារថ្ងៃត្រង់ រួចបន្តដំណើរទៅកំសាន្តនៅ ភូមិវប្បធម៌ដែលជារមណីយដ្ឋានកែច្នៃមួយ ដែលមានការទាក់ទាញ ពីភ្ញៀវជាតិនិងអន្តរជាតិ រួចបន្តដំណើរទៅទិញឥវ៉ាន់រីវត្ថុអនុស្សាវរីយ៍នៅផ្សារចាស់។ អាហារពេលល្ងាចបែបប៊ូហ្វេដ៏ច្រើនសំបូរបែបជាមួយនឹងការសំដែងរបាំបុរាណខ្មែរជូនត្រលប់ទៅសណ្ឋាគារ។

## ថ្ងៃទី៣ : សៀមរាប_បន្ទាយស្រី_ភ្នំពេញ (អាហារ ២ពេល)



អាហារពេលព្រឹករួចជូនទៅទស្សនាប្រាសាទបន្ទាយស្រី ដែលជាប្រាសាទមួយដែលមាន ក្បាច់យ៉ាងល្អជាងគេនិងបន្តទៅទស្សនា ប្រាសាទបន្ទាយសំរែ។ អាហារថ្ងៃត្រង់ រួចបន្តត្រលប់មកភ្នំពេញវិញ។

**ដំណើរកំសាន្តរួមមាន :**

- មធ្យោបាយធ្វើដំណើរដោយរថយន្តទេសចរណ៍ទំនើបមានម៉ាស៊ីនត្រជាក់
- បន្ទប់ស្នាក់នៅរួមសំរាប់គ្នា ២នាក់ក្នុងមួយបន្ទប់ ៕ សណ្ឋាគារផ្កាយ
- សំបុត្រចូលទស្សនា
- អាហារតាមកម្មវិធី១ថ្ងៃ៣ពេលនិងទឹកបរិសុទ្ធ
- សេវាកម្មពីមគ្គុទ្ទេសក៍ទេសចរណ៍
- វត្ថុអនុស្សាវរីយ៍ពី ក្រុមហ៊ុន អេស៊ាអិចផ្លរ៉ើទេសចរណ

**បញ្ជាក់:**

- ចេញដំណើររាល់ថ្ងៃសុក្រ និងថ្ងៃបុណ្យជាតិផ្សេង និងទៅតាមតំរូវការចំពោះក្រុមដែលមានគ្នា ចាប់ពី១០នាក់ឡើង។
- ក្មេងក្រោមអាយុ១២ឆ្នាំ ស្នាក់នៅជាមួយឪពុកម្តាយតំលៃ ៧៥% នៃមនុស្សពេញវ័យ
- សំរាប់ការស្នាក់នៅបន្ទប់មួយម្នាក់ឯងត្រូវបង់បន្ថែម ២០ ដុល្លារអាមេរិក

ព័ត៌មានលំអិតសូមអញ្ជើញទំនាក់ទំនង

ទូរស័ព្ទលេខ: ០២៣ ២១៨ ៦០៩

អ៊ីមែល: book@asiaexplorertravel.com